# មជ្ឈមណ្ឌលជាតិនៃជនពិការ

**National Centre of Disabled Persons**

No.3, Norodom Blvd., Phnom Penh, Cambodia. P.O Box: 170

*Tel: (855-23) 210140 ; Fax: (855-23)213876*

*Web site: http://www.ncdpcam.org*


## គោលការណ៍ ការពារសិទ្ធិកុមារ និង កុមារពិការ
## របស់មជ្ឈមណ្ឌលជាតិនៃជនពិការ

- យោងសេចក្តីថ្លែងការស្តីពីសិទ្ធិកុមារ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២
- យោងសៀវភៅដែលរៀបចំដោយ គណៈកម្មាធិការជាតិគាំទ្រឃុំ/សង្កាត់ ស្តីពីសកម្មភាព ឃុំ/សង្កាត់ នៅក្នុងកិច្ចការពារកុមារ ខែ កក្កដា ឆ្នាំ ២០០៦
- យោងគោលការណ៍បុគ្គលិករបស់មជ្ឈមណ្ឌលជាតិនៃជនពិការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧
- យោងគោលនយោបាយស្តីពីការអប់រំកុមារពិការ របស់ក្រសួងអប់រំយុវជន និងកីឡា ខែ មីនា ឆ្នាំ ២០០៨
- យោងបទដ្ឋានអប្បបរមាស្តីពី ការថែទាំជំនួសចំពោះកុមារ ខែ ឧសភា ឆ្នាំ ២០០៨

### មជ្ឈមណ្ឌលជាតិនៃជនពិការ
### សំរេច

មាត្រា១: គោលបំណង

ធ្វើទំនើបកម្មសិទ្ធិស្តីពី កិច្ចការពារកុមារពិការនៅក្នុងតំបន់គោលដៅដែល មជ្ឈមណ្ឌលជាតិនៃជនពិការ អនុវត្តសកម្មភាពរបស់ខ្លួន ។ គោលការណ៍នេះមានបំណងចូលរួមការពារ កេរ្តិ៍ឈ្មោះ គោរពសិទ្ធិមនុស្សជាទូទៅ និង ការពារតម្លៃរបស់បុគ្គលិកមជ្ឈមណ្ឌលជាតិនៃជនពិការ ។

មាត្រា២: មូលហេតុទូទៅ

- ដោយមើលឃើញសេចក្តីត្រូវការ ការរីកចំរើន និង ដៃគូអភិវឌ្ឍន៍ របស់មជ្ឈមណ្ឌលជាតិនៃជនពិការ ក្នុងការពង្រីកវិសាលភាពនៅទូទាំងប្រទេស ។ តំបន់ការងារធំទូលាយ និង ឆ្ងាយពីការិយាល័យកណ្តាល បុគ្គលិកមានកំណើនច្រើន ហើយទទួលខុសត្រូវលើការងារដោយឯករាជ្យ ។

- កុមារ និង កុមារពិការ (អនីតិជន) និង បងប្អូនពិការពេញវ័យកាយសម្បទា តែបញ្ញា ស្មារតី និង ប្រភេទពិការ មិនអាចឆ្លើយតបសិទ្ធិការពារខ្លួនបាន (នីតិជន) ក៏ត្រូវរាប់បញ្ចូលនៅក្នុងគោលការណ៍នេះដែរ ។ បញ្ហាដែលកើតឡើងក្នុងបរិបទនេះ សំរាប់កុមារ កុមារពិការ និង ជនពិការគ្រប់រូបមានដូចខាង ក្រោម ៖

  - ការចង, ការចាក់សោរបង្ខាំងកុមារឱ្យនៅតែឯង, ការប្រើអំពើហឹង្សាលើរូបរាងកាយ និង ផ្លូវចិត្ត, ការធ្វើទារុណកម្មគ្រប់រូបភាព, ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និង ផ្លូវភេទលើកុមារ ។
  - ការមិនឱ្យកុមារទៅរៀន, ទៅចូលរួមក្នុងកម្មវិធី និង សកម្មភាពសង្គម, ការមិនបង្កលក្ខណៈងាយស្រួលក្នុងការរៀនសូត្ររបស់កុមារពិការ ។
  - ការបង្អត់អាហារ, អាហាររូបត្ថម្ភ, ទឹក ឬ ការមិនអនុញ្ញាតឱ្យកុមារទទួលទានដំណេក, មិនមានការថែទាំជាពិសេសចំពោះកុមារ ។
  - ការដាក់លក្ខខណ្ឌឱ្យកុមារស្លៀកពាក់ មិនសមស្រប ឬ ប្លែកពីធម្មតា ។
  - ការមិនឱ្យកុមារទទួលការចាក់ថ្នាំបង្ការ, ការព្យាបាលជំងឺ, ការពិគ្រោះយោបល់, ការសង្គ្រោះបន្ទាន់ និង ការផ្តល់សេវាកម្មសុខភាពមិនសមស្រប ដល់កុមារពិការ ។
  - ការប្រើឱ្យកុមារ ដាក់ពិន័យគ្រប់រូបភាពលើកុមារដទៃទៀត ក្នុងគោលបំណង ឬ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនណាមួយ ។
  - ការគំរាមកំហែង ឬ ស្តីបន្ទោសកុមារ ដោយប្រើពាក្យមិនសមរម្យ ឬ អាសគ្រាម, ការធ្វើត្រាប់តាមទាំងពាក្យសំដី កាយវិការ និង ការដាក់ងារឱ្យ ។
  - ការវាយតម្លៃបន្តុះបង្អាប់អំពី អាកប្បកិរិយារបស់កុមារ ដោយគ្មានការលើកទឹកចិត្ត នៅចំពោះមុខកុមារ ឬ មនុស្សផ្សេងទៀត ។
  - ការមិនបង្កលក្ខណៈងាយស្រួល ក្នុងការបំលាស់ទីរបស់កុមារពិការនៅគ្រប់ទីកន្លែង ។
  - មិនបានបង្កលក្ខណៈងាយស្រួលដល់ ក្រុមគ្រួសារ អាជ្ញាធរមូលដ្ឋាន អ្នកសហគមន៍ និង អ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីចូលរួមក្នុងការផ្សព្វផ្សាយ ឱ្យទូលំទូលាយស្តីអំពីសិទ្ធិកុមារ ។
  - ការប្រើល្បិចកលគ្រប់រូបភាព ក្នុងគោលបំណងបោកបញ្ឆោត ដើម្បីបៀតបៀនកេរ្តិ៍ខ្មាស់ និង សេពសន្ថវៈលើកុមារ ។
  - ការប្រើសញ្ញា កាយវិការ រូបភាពអាសអាភាស ខ្សែវីដេអូ ទូរស័ព្ទ សៀវភៅ ទស្សនាវដ្តី ការស្សែត រូបថត ផ្ទាំងទស្សនីយ៍ភាព ។
  - ការថត ការប្រើប្រាស់រូបភាព របស់កុមារពិការ ដែលមានការប៉ះពាល់ទៅនឹងសិទ្ធិ, កិត្តិយស សេចក្តីថ្លៃថ្នូរ និង ប្រាស់ចាកក្រមសីលធមិវិជ្ជាជីវៈ ។

មាត្រា៣: ថ្នាក់គ្រប់គ្រង ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ ដែលធ្វើកិច្ចសហការណ៍ជាមួយ មជ្ឈមណ្ឌលជាតិនៃជនពិការ ជាពិសេសបុគ្គលិករបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវការពារ សិទ្ធិកុមារ និង ជនពិការ ទាំងនោះដូចតទៅះ

- បញ្ចៀសសកម្មភាព ដែលឈានទៅដល់ការចង, ការចាក់សោរបង្ខាំងកុមារឱ្យនៅតែឯង, ការប្រើអំពើហិង្សាលើរូបរាងកាយ និង ផ្លូវចិត្ត, ការធ្វើត្រាប់តាមទាំងពាក្យសំដី កាយវិការ និង ការដាក់ងារអោយ, ការធ្វើទារុណកម្មគ្រប់រូបភាព, ការកេងប្រវ័ញ្ច កម្លាំងពលកម្ម និង ផ្លូវភេទ លើកុមារ ។
- ត្រូវបង្កលក្ខណៈងាយស្រួលដល់ការរៀនសូត្ររបស់កុមារ និង លើកទឹកចិត្តឱ្យកុមារបានទៅ ចូលរួមក្នុងកម្មវិធីផ្សេងៗ ឬ សកម្មភាពក្នុងសង្គម ។
- ជំរុញក្រុមគ្រួសារ និង អ្នកពាក់ព័ន្ធឱ្យផ្តល់អាហារ និង អាហាររូបត្ថម្ភ, ទឹក, ឱ្យកុមារ ទទួលទានដំណោក ព្រមទាំងលើកទឹកចិត្តឱ្យមានការថែទាំជាពិសេស ចំពោះកុមារពិការ ។
- ផ្តល់យោបល់ដល់ក្រុមគ្រួសារ និង អ្នកថែទាំអោយយកចិត្តទុកដាក់ជាពិសេស ទៅលើការ ស្លៀកពាក់របស់កុមារ និង ជនពិការ អោយបានសមរម្យ និង មិនមានការបង្ខិតបង្ខំ ។
- ជួយជំរុញ និង ជួយធ្វើការសម្របសម្រួលក្នុងករណីចាំបាច់ ឬ បន្ទាន់ ដល់ក្រុមគ្រួសារ ឬ អាណាព្យាបាល និង អ្នកថែទាំ ឱ្យមានការយកចិត្តទុកដាក់ជាពិសេស ទៅលើសុខភាពរបស់កុមារ ឱ្យសមស្រប ទៅតាមកម្មវិធីថែទាំសុខភាពថ្នាក់ជាតិ ។
- ធ្វើការសម្របសម្រួល ឬ ទាក់ទងទៅអាជ្ញាធរមូលដ្ឋានក្នុងករណីចាំបាច់ និង ទប់ស្កាត់រាល់អំពើ ញុះញង់ដែលនាំឱ្យកុមារមានជម្លោះគ្នានិងគ្នា ក្នុងគោលបំណង ដើម្បីផលប្រយោជន៍បុគ្គល ណាមួយ។
- សម្របសម្រួល និង បង្កលក្ខណៈងាយស្រួល ក្នុងការបំលាស់ទីរបស់កុមារពិការនៅគ្រប់ទី កន្លែង ។
- ជំរុញដល់កុមារពិការ ក្រុមគ្រួសារ អាជ្ញាធរមូលដ្ឋាន អ្នកសហគមន៍ និង អ្នកពាក់ព័ន្ធផ្សេងៗ ទៀត ដើម្បីយល់ដឹង និង ចូលរួមក្នុងការផ្សព្វផ្សាយស្តីអំពីសិទ្ធិកុមារ សិទ្ធិស្តីពីកិច្ចការពារ និង លើកកំពស់សិទ្ធិជនពិការ និង ព័ត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធ ។
- ទំនាក់ទំនងទៅអាជ្ញាធរមូលដ្ឋាន ក្នុងការធ្វើអន្តរាគមន៍ និង ជៀសវាងដាច់ខាតរាល់សកម្មភាព ការប្រើល្បិចកលគ្រប់រូបភាព ក្នុងគោលបំណងបោកបញ្ឆោត ដើម្បីបៀតបៀនកេរ្តិ៍ខ្មាស់ និង សេពសន្ថវៈលើកុមារ ។

- ជៀសវាង រាល់ការប្រើសញ្ញា កាយវិការ រូបភាពអាសអាភាស គ្រប់ប្រភេទ និង ការថតក៏ដូចជា ការប្រើរូបភាពកុមារ ដែលមានការប៉ះពាល់ដល់សិទ្ធិ កិត្តិយស សេចក្ដីថ្លៃថ្នូរ និង ប្រាស់ចាកពីក្រមសីលធមវិជ្ជាជីវៈ ។

មាត្រា៤៖ ទោសបញ្ញត្តិ

ក្នុងករណីដែលបុគ្គលិករបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ បានប្រព្រឹត្តខុសឆ្គងក្នុងចំណុចទាំងឡាយណាដែលបានចែងក្នុង មាត្រា ៣ ខាងលើ នោះនឹងត្រូវទទួលចំណាត់ការរដ្ឋបាល ការដាក់ពិន័យ និង ទោសទណ្ឌ ដែលនឹងត្រូវអនុលោមទៅតាមនីតិវិធី, គោលការណ៍, និង ច្បាប់ ជាធរមានដូចរៀបរាប់ខាងក្រោមនេះ ៖

- គណៈកម្មាធិការក្រមសីលធមិរបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ នឹងធ្វើការវិនិច្ឆ័យសមស្របទៅតាមអំពើខុសឆ្គងដែលបានប្រព្រឹត្ត ។
- គោលការណ៍បុគ្គលិករបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ ត្រូវយកមកអនុវត្ត ។

មាត្រា៥៖ អវសានបញ្ញត្តិ

- កម្មវិធីអាចធ្វើសេចក្ដីសម្រេច ចែងលំអិតបន្ថែមទៀតនូវអត្ថន័យ និង ខ្លឹមសារ អាស្រ័យលើតម្រូវការរបស់សាមុី កម្មវិធី ឬ គ្រោងការរបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ
- ច្បាប់នេះអាចធ្វើវិសោធនកម្ម ដោយគណៈកម្មាធិការបច្ចេកទេស មជ្ឈមណ្ឌលជាតិនៃជនពិការ ក្នុងរយៈពេល ១ឆ្នាំម្តង ឬ អនុលោមទៅតាមការស្នើរសុំជាក់ស្តែងជាឯកច្ឆន្ទ និង ចាំបាច់របស់ថ្នាក់គ្រប់គ្រង របស់មជ្ឈមណ្ឌលជាតិនៃជនពិការ ឬ ពីសមាសភាព ៥០ បូកមួយរបស់គណៈកម្មាធិការបច្ចេកទេស ទៅលើកាលបរិច្ឆេទជាក់ស្តែងក្នុងការធ្វើវិសោធនកម្ម ។

មាត្រា៦៖ គោលការណ៍នេះ ស្ថិតនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃចុះហត្ថលេខា និង ប្រថាប់ត្រារបស់ មជ្ឈមណ្ឌលជាតិនៃជនពិការ តទៅ ។

ធ្វើនៅ មជ្ឈមណ្ឌលជាតិនៃជនពិការ ភ្នំពេញ, ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩

នាយកប្រតិបត្តិ

NCDP * NATIONAL CENTRE OF DISABLED PERSONS

យី វាសនា